ឆ្នាំទី២ លេខ ៤៨ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ រាជកិច្ច ទំព័រ ៣៥៦៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្របសម្រួលជាមួយសហគមន៍អ្នកផ្តល់ជំនួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

<u>ប្រការ ១</u> : ត្រូវបានបង្កើតក្រុមការងារមួយរបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងគៀងគរជំនួយ ដើម្បីបំរើអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣-ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-ឯកឧត្តម យូ ហុកគ្រី | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម ញ៉ែំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |

៦-លោកជំទាវ ស៊ុន សារឿន អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **សមាជិកា**

៧-ឯកឧត្តម នុត សារាន អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ **សមាជិក**

៨-ឯកឧត្តម សក់ សេដ្ឋា អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **សមាជិក**

៩-ឯកឧត្តម ចៅ វណ្ណលី អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **សមាជិកអចិន្ត្រៃយ៍**

<u>**ប្រការ ២**</u> : ក្រុមការងារនេះមានភារកិច្ច :

- សិក្សាប៉ាន់ប្រមាណអំពីតម្រូវការនានា សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយនានា ដើម្បីពិភាក្សាសម្របសម្រួលស្វះស្វែងរកជំនួយបំរើអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ពិភាក្សាស្វះស្វែងរកការគាំទ្រពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។
- រៀបចំអោយមានកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ឬជាមួយសហគមន៍អ្នកផ្តល់ជំនួយ ឬជាមួយសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិតាមការចាំបាច់ ។

<u>**ប្រការ ៣**</u> : ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិការបស់គណៈរដ្ឋមន្ត្រី ។

<u>**ប្រការ ៤**</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**កន្លែងទទួល :**</u>

*-ទីស្តីការក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*-តំណាងអង្គការ UNDP ប្រចាំកម្ពុជា*
*- ដូចប្រការ៤*
*- ឯកសារ-កាលប្បវត្តិ*